# ប្រព័ន្ធទិន្នន័យអេឡិចត្រូនិកសម្រាប់កម្មវិធីគាំទ្រដំបូងរបស់ទារក និងកុមារតូចៗ (ESIT)

ព័ត៌មានខាងក្រោមគឺសម្រាប់ក្រុមគ្រួសារនៅក្នុងប្រព័ន្ធសេវាកម្មអន្តរាគមន៍ដំបូង ដើម្បីពន្យល់ពីរបៀបដែល *ESIT* ប្រមូល និងរក្សាទុកទិន្នន័យរបស់គ្រួសារ/កុមារនៅក្នុងប្រព័ន្ធទិន្នន័យ *ESIT*។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ៖ ***www.dcyf.wa.gov/services/child-dev-support-providers/esit***

## ហេតុអ្វីបានជាទិន្នន័យរបស់គ្រួសារខ្ញុំត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យ ESIT ?

ដើម្បីជួយដល់អ្នកសម្របសម្រួលធនធានគ្រួសារ (FRC) និងអ្នកផ្តល់សេវាកម្មក្នុងការផ្តល់សេវាកម្មឲ្យបានទាន់ពេលវេលា និងស្របតាមសិទ្ធិមាតាបិតា/សិទ្ធិកុមារដូចបានកំណត់ចែងក្នុងច្បាប់អប់រំបុគ្គលដែលមានភាពពិការ (IDEA) ត្រង់ផ្នែក C។ ប្រព័ន្ធទិន្នន័យបង្កើតដោយស្វ័យប្រវត្តិនូវរបាយការណ៍សហព័ន្ធ និងរដ្ឋដែលចាំបាច់ដើម្បីទទួលបានមូលនិធិថ្នាក់មូលដ្ឋាន រដ្ឋ និងសហព័ន្ធសម្រាប់សេវាកម្ម។ ទិន្នន័យសម្រាប់កម្រិតកុមារទាំងអស់ត្រូវបានរាយការណ៍ដោយអនាមិកសម្រាប់រាយការណ៍ថ្នាក់រដ្ឋ និងសហព័ន្ធ។ ព័ត៌មានត្រូវបានប្រមូលដើម្បីកំណត់សិទ្ធិរបស់កូនអ្នកសម្រាប់ការទទួលបានសេវាកម្មអន្តរាគមន៍ដំបូង និងដើម្បីបង្កើតផែនការសេវាកម្មគ្រួសារលក្ខណៈបុគ្គល (IFSP)។

ប្រព័ន្ធទិន្នន័យជួយដល់អ្នកផ្តល់សេវា FRCs និង ESIT ក្នុងការធានាថាសេវាកម្មត្រូវបានផ្តល់ជូនស្របតាមច្បាប់ IDEA ត្រង់ផ្នែក C។

## តើព័ត៌មានរបស់ខ្ញុំមានសុវត្ថិភាពដែរឬទេ ?

មាន! ព័ត៌មានរបស់អ្នកត្រូវបានរក្សាទុកដោយមានការការពារសុវត្ថិភាពបួនកម្រិត។ វាក៏ត្រូវបានបញ្ចូលប្រប្លុកប្រូចល់គ្នាផងដែរ នៅពេលដែលវាផ្ទេរពីកុំព្យូទ័ររបស់ FRC របស់អ្នក និងប្រព័ន្ធទិន្នន័យ។

## តើទិន្នន័យរបស់ខ្ញុំត្រូវបានរក្សាទុកនៅឯណា ?

ព័ត៌មានរបស់អ្នកនឹងត្រូវរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យ និងពាក្យសម្ងាត់ដែលការពារដោយអ្នកផ្តល់សេវា FRC និង ESIT របស់អ្នក។

ព័ត៌មានរបស់អ្នកនឹងត្រូវបានរក្សាទុកនៅក្នុងឃ្លាំងទិន្នន័យដែលមានសុវត្ថិភាពដែលថែរក្សាដោយកម្មវិធី ESIT។ ទិន្នន័យមិនអាចចូលមើលបានតាមរយៈអ៊ីនធឺណិតទេ ហើយព័ត៌មានក៏មិនត្រូវបានរក្សាទុកនៅលើអ៊ីនធឺណិតដែរ។

ឯកសារជាក្រដាសមួយចំនួននៅតែត្រូវការជាចាំបាច់ ហើយនឹងត្រូវបានរក្សាទុកយ៉ាងមានសុវត្ថិភាពជាមួយ FRC របស់អ្នក។

## តើនរណាអាចចូលមើលព័ត៌មានគ្រួសាររបស់ខ្ញុំបាន ?

មានតែ FRC ដែលជាអ្នកផ្តល់សេវា ESIT និង DCYF ESIT ប៉ុណ្ណោះដែលមានសិទ្ធិចូលមើលព័ត៌មានលម្អិតអំពីគ្រួសាររបស់អ្នកបាន។ FRC និងអ្នកផ្តល់សេវា ESIT អាចផ្តល់សិទ្ធិឱ្យសមាជិកផ្សេងទៀតរបស់ក្រុម IFSP ចូលមើលព័ត៌មានបានតែបន្ទាប់ពីអ្នកបានផ្តល់ការយល់ព្រមរបស់អ្នកប៉ុណ្ណោះ។

ប្រព័ន្ធទិន្នន័យ ESIT ត្រូវតែបន្តបំពេញតាមលក្ខខណ្ឌនៃច្បាប់ស្តីពីសិទ្ធិនៃការអប់រំរបស់គ្រួសារ និងសិទ្ធិឯកជន (FERPA)។ នេះជាការពិតសម្រាប់កំណត់ត្រាទាំងអស់មិនថាផ្ទុកតាមអេឡិចត្រូនិច ឬលើក្រដាសទេ។

អ្នកផ្តល់សេវា ESIT និងកម្មវិធី DCYF ESIT នឹងមានសិទ្ធិចូលមើលរបាយការណ៍សង្ខេបអំពីកុមារ និងក្រុមគ្រួសារដែលទទួលបានសេវាកម្មអន្តរាគមន៍ដំបូង។ បុគ្គលិកកម្មវិធី ESIT នឹងមានសិទ្ធិអានចំពោះតែព័ត៌មានរបស់គ្រួសារនីមួយៗប៉ុណ្ណោះ។

មាតាបិតាអាចស្នើសុំរបាយការណ៍ពី FRC របស់ពួកគេដោយបង្ហាញមនុស្សទាំងអស់ដែលបានចូលមើលព័ត៌មានគ្រួសាររបស់ពួកគេ។

## តើគេនឹងប្រមូលព័ត៌មានអ្វីខ្លះ ?

ព័ត៌មានដែលទទួលបានពីគ្រួសាររបស់អ្នកនឹងត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ FRC របស់អ្នកអាចផ្តល់ឱ្យអ្នកនូវបញ្ជីពេញលេញ និងច្បាប់ចម្លងនៃព័ត៌មានដែលប្រមូល និងរក្សាទុកនៅលើប្រព័ន្ធអេឡិចត្រូនិក។

សេចក្តីថ្លែងរបស់គ្រួសារអ្នកដែលរាប់បញ្ចូលទាំងក្តីកង្វល់ អាទិភាព និងធនធានរបស់អ្នកនៅតែបន្តស្ម័គ្រចិត្ត និងអាចចូលមើលដោយ FRC របស់អ្នក អ្នកផ្តល់សេវា ESIT និងបុគ្គលិក DCYF ESIT ប៉ុណ្ណោះ។

## តើខ្ញុំអាចមើលឃើញព័ត៌មានអ្វីខ្លះនៅក្នុងប្រព័ន្ធអំពីគ្រួសាររបស់ខ្ញុំ ?

គន្លឹះរបស់អ្នកក្នុងការចូលមើលព័ត៌មានគឺតាមរយៈផតថល Parent Portal និង FRC របស់អ្នក។

## ប្រសិនបើខ្ញុំមិនចង់ឲ្យព័ត៌មានគ្រួសារខ្ញុំផ្ទុកនៅក្នុងប្រព័ន្ធនេះតើខ្ញុំនៅតែអាចចូលរួមបានទេ ?

ប្រសិនបើអ្នកចង់ចូលរួមក្នុងសេវាកម្មអន្តរាគមន៍ដំបូង ចំនួនព័ត៌មានអប្បបរមារបស់អ្នកចាំបាច់ត្រូវប្រមូលផ្ទុកទៅក្នុងប្រព័ន្ធទិន្នន័យ ESIT ដែលជាផ្នែកមួយនៃសិទ្ធិអំណាចសហព័ន្ធ និងរដ្ឋរបស់យើង។

---

បើអ្នកចង់បានច្បាប់ចម្លងនៃឯកសារនេះជាទម្រង់ ឬភាសាផ្សេង សូមទាក់ទងផ្នែកទំនាក់ទំនង *DCYF* តាមលេខ
*(1-800-723-4831 | 360-902-8060, **ConstRelations@dcyf.wa.gov**)*

DCYF PUBLICATION FS_0012 CA (03-2021) Cambodian